# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយបុគ្គលិកអង្គការការីតាសទាំងអស់
# មណ្ឌលគិរី ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០
## បង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់

**អត្ថបទទី១៖ សាមូអែលទី១ ១៧,៣២-៣៣.៣៧.៤០-៥១**
សហគមន៍នៃជនជាតិអ៊ីស្រាអែលទាំងមូលនឹងដឹងថា ព្រះអម្ចាស់ប្រទានឲ្យយើងមានជ័យជម្នះ ពុំមែនដោយដាវ ឬលំពែងទេ ដ្បិតព្រះអម្ចាស់ច្បាំងជំនួសយើង ព្រះអង្គនឹងប្រគល់ពួកឯងមកក្នុងកណ្តាប់ដៃរបស់ពួកយើង»។ ១សម ១៧,៤៧
**ដំណឹងល្អ៖ ម៉ាកុស ៣,១-៦**
ព្រះអង្គមានព្រះបន្ទូលសួរទៅគេថា៖ «នៅថ្ងៃសប្ប័ទ តើច្បាប់អនុញ្ញាតឲ្យធ្វើអំពើល្អ ឬធ្វើអំពើអាក្រក់? តើត្រូវសង្គ្រោះមនុស្ស ឬប្រហារជីវិតចោល?»។ មក ៣,៤

បងប្អូនជាទីស្រឡាញ់!

អត្ថបទដែលយើងស្តាប់ថ្ងៃនេះ ព្រះយេស៊ូកំពុងចូលនៅក្នុងធម្មសាលា មានម្នាក់ដែលពិការដៃពីដើម ថ្ងៃនោះជាថ្ងៃសប្ប័ទ តាមសាសនាយូដានៅថ្ងៃសប្ប័ទអត់មានសិទ្ធិធ្វើការ អត់មានសិទ្ធិធ្វើអ្វីសោះ។ គេកំពុងលួចមើលព្រះយេស៊ូ ហើយគេចង់ដឹងនៅពេលព្រះយេស៊ូឃើញមនុស្សម្នាក់ដែលកំពុងស្វិតដៃពីកំណើត **តើព្រះយេស៊ូនឹងធ្វើអ្វីខ្លះ?** ព្រះយេស៊ូស្គាល់ចិត្តរបស់គេដូច្នេះព្រះអង្គសួរគេថា **តើថ្ងៃសប្ប័ទយើងត្រូវធ្វើអំពើល្អឬអំពើអាក្រក់? ប្រហារជីវិតឬណែនាំឲ្យគេមានជីវិត?** ព្រះយេស៊ូចង់ប្រើពាក្យធ្ងន់ឲ្យគេភ្ញាក់ស្មារតី ព្រះយេស៊ូថាសូមលាតដៃមើលទៅ ហើយទាំងអស់គ្នាឃើញព្រះយេស៊ូណែនាំឲ្យអ្នកពិការដៃនោះជាសះស្បើយ។ ពួកខាងគណៈផារីស៊ី ដែលចង់រករឿងព្រះយេស៊ូគេចេញពីធម្មសាលាស្ងាត់ៗ និងចាប់ផ្តើមរកមធ្យោបាយដើម្បីសម្លាប់ព្រះយេស៊ូ។ ព្រះយេស៊ូបានធ្វើខុសធម្មវិន័យនៅថ្ងៃសប្ប័ទ ក៏ប៉ុន្តែព្រះយេស៊ូណែនាំឲ្យមនុស្សមានជីវិត។ ដូច្នេះ សម្រាប់យើងទាំងអស់ដែលយើងបានស្តាប់ថ្ងៃនេះ ត្រូវទៅជាគោលដៅនៃបេសកកម្មរបស់យើងមិនមែនតែទស្សនៈ ប៉ុន្តែបេសកកម្មគឺរបៀបដែលយើងអនុវត្តមានចិត្តអាណិតមេត្តា។ នេះជារបៀបព្រះយេស៊ូ ពេលគាត់ឃើញមនុស្សម្នាក់មានសេចក្តីត្រូវការ ព្រះយេស៊ូរកមធ្យោបាយដើម្បីឲ្យមនុស្សនោះអាចមានសេចក្តីសង្ឃឹមសាជាថ្មី។ ប៉ុន្តែ ជូនកាលណែនាំឲ្យយើងធ្វើខុសនឹងប្រពៃណី ខុសនឹងទម្លាប់ ធម៌មេត្តាករុណាត្រូវការណែនាំគ្រប់បេសកកម្មរបស់យើង ដោយដឹងថាមានមនុស្សមួយចំនួនរិះគន់យើង មានមនុស្សមួយចំនួនមិនពេញចិត្តនិងយើង។

សង្គមបច្ចុប្បន្ននេះ មិនរវីរវល់ប៉ុន្មានទេជាមួយអ្នកក្រីក្រ ជាមួយអ្នកពិការ ជាមួយមនុស្សដែលអត់ស្ងួរគ្រប់ ជាមួយមនុស្សដែលគ្មានសមត្ថភាព ជាមួយមនុស្សដែលគ្មានចំណេះដឹង ក៏ប៉ុន្តែយើងធ្វើដូចម្តេចដើម្បីសង្គ្រោះមនុស្សទាំងនោះ។ ព្រឹកមិញ យើងឃើញផ្ទាល់ភ្នែកប៉ុន្មានឆ្នាំមុនកូនក្មេងក្នុងភូមិស្រែអ៊ីរស់នៅក្នុងព្រៃ អាចនិយាយថាដាច់ស្រយាលនៃផែនដីនៃប្រទេសកម្ពុជា។ នៅពេលរដ្ឋមន្ត្រីបរិស្ថាន ជាមួយរតនានិងបុគ្គលិកការីតាសនៅឆ្នាំ២០១៥ បានទៅដល់ឃើញកូនក្មេងទាំងនោះមានចិត្តអាណិតមេត្តា រកមធ្យោបាយដើម្បីឲ្យក្មេងនេះមានការសិក្សាដើម្បីមានអនាគតល្អ។ ថ្ងៃនេះ យើងឃើញនៅពេលឡើងសន្ទរកថា កូនក្មេងគេស្តាប់បាននិងពោរពេញដោយក្តីសង្ឃឹមសម្រាប់អនាគតគេ ប្រហែលឪពុកម្តាយស្តាប់អត់ស្ងួរបានទេ។ យើងបានឆ្លើយតបសេចក្តីត្រូវការរបស់មនុស្សតូចតាច ដែលមិនសូវមានគេចាប់អារម្មណ៍ទេ យើងគិតពិចារណាសព្វថ្ងៃនៅប្រទេសកម្ពុជា មានកូនក្មេងប៉ុន្មាននាក់ដែលអត់មានសិទ្ធិទៅរៀន។ វាជារឿងអយុត្តិធម៌យើងត្រូវការគិតពិចារណា យើងដែលរស់នៅក្នុងគោលដៅបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។

ពេលយើងនិយាយអំពីធម៌មេត្តាករុណា ជួនកាលយើងអត់ស្ងួរយល់ពីអត្ថន័យនៃសេចក្តីស្រឡាញ់ នៅក្នុងអត្ថបទដែលយើងបានស្តាប់ថ្ងៃនេះ យើងបានស្តាប់ទាំងអស់អំពីសេចក្តីស្រឡាញ់។ អ្នកមានចិត្តស្រឡាញ់ តែងតែអត់ធ្មត់ ជួយធុរៈគេ មិនចេះឈ្នានីសគេ។ អ្នកមានចិត្តស្រឡាញ់ មិនវាយឫកខ្ពស់ មិនអួតបំប៉ោងឡើយ។ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនម៉ូម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិត។ ប្រហែលយើងអាចបិទអត្ថបទនេះលើជញ្ជាំងរបស់យើង នៅតាមការិយាល័យនីមួយៗ ដើម្បីឲ្យយើងយល់ពីអត្ថន័យនៃសេចក្តីស្រឡាញ់ ចិត្តអត់ធ្មត់ មិនមានអំណួតនៅក្នុងខ្លួន មិនសប្បាយចិត្តនៅពេលមានអំពើទុច្ចរិត។ ផ្ទុយទៅវិញ អ្នកដែលមានចិត្តស្រឡាញ់យកចិត្តទុកដាក់ជានិច្ច ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗរកឃើញសេចក្តីសង្ឃឹមនៅក្នុងជីវិត។ ជំនឿសំខាន់ សេចក្តីសង្ឃឹមក៏សំខាន់ដែរ ប៉ុន្តែគុណធម៌ គុណតម្លៃសំខាន់បំផុតគឺសេចក្តីស្រឡាញ់។ ដូច្នេះ ពេលយើងចេះសម្តែងសេចក្តីស្រឡាញ់រវាងគ្នានិងគ្នា យើងដឹងថាយើងដើរតាមផ្លូវត្រឹមត្រូវ។ ទោះបីមានគេរិះគន់ ទោះបីគេចង់ទិតៀន ទោះបីគេនិយាយដើមយើង យើងដឹងថានេះជាផ្លូវដែលយើងត្រូវតែដើរទៅមុខ។ អង្គការការីតាស មានន័យថាអង្គការមេត្តាករុណា យើងមានសំណាងដែលយើងទាំងអស់គ្នាធ្វើការនៅក្នុងអង្គការមួយដែលបង្ហាញធម៌មេត្តាករុណា។

ដូច្នេះ ឲ្យយើងថែរក្សាអំណរសប្បាយដែលយើងមាននៅក្នុងគ្រួសារការីតាស ដោយដឹងថាយើងជួយគ្នាទៅវិញទៅមកដើម្បីបង្កើតគ្រួសារមួយដែលថែរក្សាបងប្អូនឯទៀតៗ។ នេះយើង

មានធម្មជាតិមែន  ក៏ប៉ុន្តែកំពូលនៃពិភពលោកគឺមនុស្សយើងដែលមានតម្លៃថ្លៃថ្នូរ។  យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គគង់នៅជាមួយយើង ដើម្បីឲ្យយើងទៅមុខតទៅទៀត។ អាម៉ែន៕